**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណបក្ស ភ្លើងទៀន**
CANDLE LIGHT PARTY

# លក្ខន្តិកៈគណបក្ស

## បុព្វកថា

ចាប់តាំងពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ មក ប្រទេសជាមិត្តបានចាប់ផ្តើមជំរុញឱ្យមានសន្តិភាព និងលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា។ ក្រោមការតាមដាន និងត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ អាជ្ញាធរបណ្តោះអាសន្នហៅកាត់ថា អ៊ុនតាក់ បានផ្តួចផ្តើមគំនិតឱ្យមានការរៀបចំនូវការបោះឆ្នោតដោយសេរីត្រឹមត្រូវមួយ នៅខែឧសភា ឆ្នាំ១៩៩៣ ដែលបានផ្តល់ជ័យជម្នះ ឱ្យកម្លាំងអ្នកស្នេហាជាតិ និងប្រជាធិបតេយ្យ។ លទ្ធផលនៃការបោះឆ្នោតនោះ សឲ្យឃើញថាប្រជារាស្ត្រខ្មែរចង់ឱ្យមានការផ្លាស់ប្តូររបបនយោបាយគ្រប់គ្រងប្រទេស និងរបៀបរៀបចំសង្គមជាតិឱ្យបានទទួលនូវការរីកចម្រើន ប្រកបដោយសេរីភាព និងយុត្តិធម៌។ ប្រជារាស្ត្រខ្មែរក៏បានសម្តែងផងដែរ នូវឆន្ទៈរបស់លោក ចង់ឱ្យប្រទេសកម្ពុជា ទទួលបានឡើងវិញនូវឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីពេញលេញ។ ប៉ុន្តែអ្វីដែលជាក្តីសង្ឃឹមនៃប្រជារាស្ត្រខ្មែរនៅពេលនោះ មិនទាន់បានសម្រេច ដោយសារបញ្ហាជាតិធំៗ ដូចជាអំពើពុករលួយ ភាពក្រីក្រ អយុត្តិធម៌សង្គម ការកាប់បំផ្លាញព្រៃឈើ ការរំលោភសិទ្ធិមនុស្ស បូរណភាពទឹកដី អន្តោប្រវេសន៍ខុសច្បាប់ មិនទាន់ត្រូវបានដោះស្រាយទាំងស្រុងនៅឡើយ ។

នៅក្នុងកាលៈទេសៈនោះហើយ ដែលគណបក្សជាតិខ្មែរត្រូវបានបង្កើតឡើងនៅថ្ងៃទី០២ ខែវិច្ឆិកា ហើយដែលត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ដើម្បីប្រមូលផ្តុំកម្លាំងអ្នកស្នេហាជាតិ និងប្រជាធិបតេយ្យ ដែលចង់កសាង និងរៀបចំប្រទេសឡើងវិញឱ្យបានល្អត្រឹមត្រូវ ផ្អែកលើគោលការណ៍ **សីលធម៌ សច្ចធម៌ និងយុត្តិធម៌ ។**

ទោះបីគណបក្សជាតិខ្មែរ បានបំពេញបែបបទត្រឹមត្រូវ និងគ្រប់គ្រាន់ តាមផ្លូវច្បាប់ហើយក៏ដោយ ក៏ក្រសួងមហាផ្ទៃ នៅតែបដិសេធមិនទទួលស្គាល់គណបក្សជាតិខ្មែរ ដោយយកលេសថា ឈ្មោះគណបក្សជាតិខ្មែរ មានឈ្មោះដូចគ្នានឹងគណបក្សដទៃ ដែលរៀបចំឡើងដោយជនខិលខូចមួយក្តាប់តូច ។ ដោយសារស្ថានភាពបែបនោះហើយ ទើបមុនពេលបោះឆ្នោតខែកក្កដា ឆ្នាំ១៩៩៨ បន្តិច គឺនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ គណបក្សជាតិខ្មែរ បានប្រារព្ធធ្វើសមាជវិសាមញ្ញមួយ ដោយត្រូវបង្ខំចិត្តក្នុងឱកាសនោះប្តូរឈ្មោះ

លេខាធិការគណបក្សភ្លើងទៀន

គណបក្សជាតិខ្មែររបស់ខ្លួន ទៅជាគណបក្សសម រង្ស៊ី ដោយយកតាមឈ្មោះលោកប្រធានស្ថាបនិក សម រង្ស៊ី ដើម្បីធានាមិនឱ្យមានការលួច ឬបន្លំយកឈ្មោះគណបក្សទៅបម្រើឱ្យជនខិលខូច។ គណបក្សក៏បានកំណត់យករូប "**ទៀនមានពន្លឺ**" ជាសញ្ញាសម្គាល់ផងដែរ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ គណបក្សសម រង្ស៊ី បានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសម្រាប់អាណត្តិទី២ តែដោយការបោះឆ្នោតនៅពេលនោះ មិនបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ធ្វើឱ្យគណបក្ស សម រង្ស៊ី ទទួលបានអាសនៈតំណាងរាស្ត្រតែ ១៥ រូបប៉ុណ្ណោះនៅក្នុងរដ្ឋសភា។ បន្ទាប់ពីមានមហាបាតុកម្មរបស់ប្រជារាស្ត្រខ្មែរប្រឆាំងនឹងលទ្ធផលនៃការបោះឆ្នោត នៅចុងឆ្នាំ ១៩៩៨ រដ្ឋាភិបាលចម្រុះរបស់ពីរគណបក្សផ្សេងទៀត ដែលមានអាសនៈនៅក្នុងរដ្ឋសភា ត្រូវបានបង្កើតឡើង តែរដ្ឋាភិបាលពេលនោះ នៅតែបន្តអនុវត្តនយោបាយដូចពេលមុនៗ ដោយរក្សាតួនាទីអ្នកដឹកនាំពីមុនដដែល ជាហេតុធ្វើឱ្យប្រទេសកម្ពុជាស្ថិតក្នុងស្ថានភាពអាប់អួរ និងជុនជាប។ ក្នុងកាលៈទេសៈនោះ គណបក្ស សម រង្ស៊ី បានក្លាយទៅជាគណបក្សជំទាស់តែមួយគត់ ដើម្បីប្រកួតប្រជែងក្នុងការកសាងប្រទេសឱ្យបានល្អត្រឹមត្រូវ។ ក្នុងន័យនេះហើយ គណបក្ស សម រង្ស៊ី គឺជាតំណាងឆន្ទៈពិតប្រាកដរបស់ប្រជារាស្ត្រខ្មែរ ដែលជាក្តីសង្ឃឹមតែមួយគត់ របស់ប្រជារាស្ត្រក្នុងការការពារផលប្រយោជន៍ជាតិ ជំរុញឱ្យលទ្ធិប្រជាធិបតេយ្យរីកចម្រើន ការគោរពសិទ្ធិមនុស្ស លើកស្ទួយជីវភាពប្រជាពលរដ្ឋ និងលើកតម្កើងយុត្តិធម៌សង្គម ព្រមទាំងការពារឯករាជ្យភាពជាតិ និងបូរណភាពទឹកដីឱ្យបានគង់វង្ស។

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ គណបក្ស សម រង្ស៊ី បានប្រារព្ធធ្វើសមាជវិសាមញ្ញមួយ ហើយបានសម្រេចក្នុងឱកាសនោះ ប្តូរឈ្មោះគណបក្ស សម រង្ស៊ី ទៅជា "**គណបក្ស ភ្លើងទៀន**" ដើម្បីឱ្យស្របតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់គណបក្សនយោបាយ ដោយគណបក្សបានកំណត់រក្សារូប "**ភ្លើងទៀនមានពន្លឺ**" ជាសញ្ញាសម្គាល់ និងមានបាវចនា "**សីលធម៌ សច្ចធម៌ យុត្តិធម៌**" ដដែល។

អង្គសមាជវិសាមញ្ញ បានសម្រេចផងដែរ ដូចខាងក្រោម៖

- ពង្រីក និងពង្រឹងកម្លាំងស្នេហាជាតិ និងប្រជាធិបតេយ្យឱ្យកាន់តែរឹងមាំ
- កែលម្អរចនាសម្ព័ន្ធគ្រប់គ្រង និងធ្វើវិសោធនកម្មលើមាត្រាមួយចំនួន នៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងឱ្យស្របទៅតាមស្ថានការណ៍នយោបាយបច្ចុប្បន្នរបស់ប្រទេស
- កំណត់ និងរៀបចំផែនការយុទ្ធសាស្ត្រ និងយុទ្ធវិធីផ្សេងៗ ដើម្បីសម្រេចគោលដៅរបស់គណបក្ស។

## ជំពូកទី ១
## បញ្ញត្តិទូទៅ

**ប្រការ ១** : គណបក្ស សម រង្ស៊ី ដែលបានបន្តការងាររបស់គណបក្សជាតិខ្មែរ ដែលត្រូវបានបង្កើតឡើងដោយប្រជាពលរដ្ឋខ្មែរ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ហើយបានប្រកាសជាផ្លូវការនៅរាជធានីភ្នំពេញ នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ហើយត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃ តាមប្រកាសលេខ ១៩៣ ប្រ.ក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ត្រូវបានប្តូរឈ្មោះមកជា **គណបក្ស ភ្លើងទៀន** សរសេរអក្សរកាត់ **"គ.ភ.ទ"** ។

**ប្រការ ២** : គណបក្សភ្លើងទៀន ប្រព្រឹត្តទៅក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣** : ទីស្នាក់ការកណ្តាលរបស់គណបក្ស តាំងនៅរាជធានីភ្នំពេញ នៅផ្ទះលេខ ២០៩ ផ្លូវលំអូរអំពិល សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ ទីស្នាក់ការនេះ អាចប្តូរទីតាំងទៅកន្លែងផ្សេងទៀតបាន តាមការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

គណបក្សមានសាខានៅទូទាំងប្រទេស និងតាមបណ្តាប្រទេសនានា លើសកលលោក ដែលមានជនជាតិខ្មែររស់នៅ ដោយកំណត់ និងផ្អែកទៅតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

**ប្រការ ៤** : គណបក្សភ្លើងទៀន មានរូប **"ទៀនមានពន្លឺ"** ជាសញ្ញាសម្គាល់ និងមានបាវចនា **"សីលធម៌ សច្ចធម៌ យុត្តិធម៌"** ។ អត្ថន័យនៃរូបសញ្ញានេះ មានចែងនៅក្នុងឧបសម្ព័ន្ធ១ ។

## ជំពូកទី ២
## គោលនយោបាយ

**ប្រការ ៥** : គណបក្ស ភ្លើងទៀន មានគោលនយោបាយដូចតទៅ ៖

១- ប្រឆាំង និងបំបាត់រាល់អំពើហិង្សាក្នុងសង្គម ធានាសុខសន្តិភាពពេញលេញ ជូនប្រជាពលរដ្ឋ និងសន្តិភាពពិតប្រាកដ ជូនប្រទេសជាតិ

២- ការពារ និងលើកតម្កើងសិទ្ធិមនុស្ស អនុវត្តលទ្ធិប្រជាធិបតេយ្យសេរី ឱ្យបានត្រឹមត្រូវ និងពិតប្រាកដ

៣- បំបាត់អំពើពុករលួយគ្រប់បែបយ៉ាង ពិសេសរៀបចំប្រព័ន្ធតុលាការឡើងវិញ ឱ្យមានភាពស្អាតស្អំ ផ្តល់យុត្តិធម៌ជូនជនរងគ្រោះ

៤- លើកតម្កើងយុត្តិធម៌សង្គម ជួយអ្នកក្រីក្រឱ្យមានជីវភាពសមរម្យ និងប្រែប្រួល កម្រិតប្រាក់ខែជូនបុគ្គលិកមន្ត្រីរាជការ ជួយប្រជាពលរដ្ឋទាំងអស់ឲ្យមានសមភាពស្មើគ្នាក្នុងការកសាងអនាគតរបស់ខ្លួន

៥- ធានាអព្យាក្រឹត្យភាពរដ្ឋបាលសាធារណៈ ឱ្យមានឯករាជ្យភាពពីគ្រប់គណបក្សនយោបាយ បម្រើប្រជារាស្ត្រ ដោយមិនប្រកាន់បក្ខពួក

៦- រៀបចំប្រព័ន្ធគ្រប់គ្រងដីធ្លីឡើងវិញ ការពារសិទ្ធិរបស់ប្រជារាស្ត្រ ហើយប្រគល់សងជូនប្រជារាស្ត្រវិញនូវដីធ្លីណា ដែលអ្នកកាន់អំណាចពុករលួយ និងឈ្មួញទុច្ចរិតបានលួចប្លន់ពីរាស្ត្រ ផ្ដល់ឱ្យកសិករគ្រប់រូបមានស្រែចំការ ផ្ដល់ឱ្យពលរដ្ឋគ្រប់គ្រួសារមានទីជម្រកសមរម្យ

៧- ការពារព្រំដែនប្រទេសកម្ពុជា ធានាបូរណភាពទឹកដីឱ្យបានគង់វង្ស

៨- ដោះស្រាយបញ្ហាជនអន្តោប្រវេសន៍ដែលមករស់នៅដោយខុសច្បាប់

៩- បញ្ឈប់ការកាប់បំផ្លាញព្រៃឈើ ការពាររាល់ទ្រព្យសម្បត្តិសាធារណៈ សម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌របស់ប្រទេសជាតិ ឱ្យបានគង់វង្ស

១០- ពិនិត្យ និងកែតម្រូវឡើងវិញរាល់កិច្ចសន្យាទាំងឡាយណារវាងរដ្ឋាភិបាល និងក្រុមហ៊ុនឯកជន ដែលមិនស្របច្បាប់ មិនបម្រើឱ្យផលប្រយោជន៍ប្រទេសជាតិ និងប្រជារាស្ត្រ។

## ជំពូកទី ៣
## សមាជិកភាព

**ប្រការ ៦** : គណបក្ស ភ្លើងទៀន គឺជាអង្គការនយោបាយប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរី និងបើកចំហយ៉ាងទូលំទូលាយ ទទួលយកប្រជាពលរដ្ឋខ្មែរ ពីគ្រប់មជ្ឈដ្ឋាន ដែលគាំទ្រគោលនយោបាយរបស់គណបក្សជាសមាជិករបស់ខ្លួន។ អាយុអប្បបរមារបស់សមាជិកគណបក្ស គឺ ១៨ ឆ្នាំពេញលេញ នៅថ្ងៃដែលអនុញ្ញាតឱ្យចូលជាសមាជិក។

**ប្រការ ៧** : សមាជិកគណបក្ស ចែកចេញជា ៥ប្រភេទ ៖

១- សមាជិកស្ថាបនិក

២- សមាជិកសកម្ម

៣- សមាជិកកិត្តិយស

៤- សមាជិកឧបត្ថម្ភ

៥– សមាជិកបាសាទិកៈ

**ប្រការ ៨** : សមាជិកស្ថាបនិក គឺជាសមាជិកទាំងឡាយណា ដែលបានផ្ដើមគំនិត និងបានចូលរួមបង្កើតគណបក្សមុនថ្ងៃប្រកាសជាផ្លូវការនៅរាជធានីភ្នំពេញ នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ។

**ប្រការ ៩** : សមាជិកសកម្ម គឺជាសមាជិកទាំងឡាយណា ដែលបានដាក់ពាក្យជាលាយលក្ខណ៍អក្សរចូលជាសមាជិករបស់គណបក្សក្រោយថ្ងៃប្រកាសបង្កើតគណបក្សជាផ្លូវការ ហើយដែលបញ្ចេញសកម្មភាពគាំទ្រ បម្រើគណបក្សប្រកបដោយភាពមោះមុតនិងស្មោះត្រង់។

**ប្រការ ១០** : សមាជិកកិត្តិយសគឺជាវរជនដែលមានឈ្មោះល្បីល្បាញលើឆាកជាតិ និងអន្តរជាតិ ដែលបានសុខចិត្តជួយជ្រោមជ្រែងដល់គណបក្ស។

**ប្រការ ១១** : សមាជិកឧបត្ថម្ភ គឺជាសមាជិក ដែលបានធ្វើអំណោយយ៉ាងសំខាន់ជាវត្ថុ ឬជាទឹកប្រាក់ដល់គណបក្ស។

**ប្រការ ១២** : សមាជិកបាសាទិកៈគឺជាសមាជិកដែលរស់នៅក្នុងប្រទេស និងក្រៅប្រទេសដែលមិនអាចចូលរួមយ៉ាងសកម្មក្នុងសកម្មភាពគណបក្សដោយផ្ទាល់បាន ប៉ុន្តែជាអ្នកគាំទ្រគណបក្សយ៉ាងម៉ឺងម៉ាត់បំផុត។

**ប្រការ ១៣** : សមាជិកទាំងអស់របស់គណបក្ស ដោយគ្មានការលើកលែងដល់នរណាម្នាក់ ត្រូវអនុវត្តតាមបញ្ញត្តិនានា ដែលមានចែងក្នុងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់គណបក្ស ហើយត្រូវអនុវត្តតាមគោលនយោបាយ និងសេចក្តីសម្រេចនានារបស់គណបក្ស ដូចជាសេចក្តីសម្រេចរបស់សមាជ របស់គណៈកម្មាធិការនាយក និងរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។

**ប្រការ ១៤** : សមាជិកគណបក្សទាំង ៥ ប្រភេទ ដែលបង្ហាញនូវទង្វើណាមួយក្នុងការជួយគណបក្សគួរឱ្យកត់សម្គាល់ អាចទទួលបាន"**មេដាយពន្លឺភ្លើងទៀន**"។ ប្រភេទ និងកម្រិត មេដាយពន្លឺភ្លើងទៀន មានចែងក្នុងជំពូក ៦ នៃបទបញ្ជាផ្ទៃក្នុងគណបក្ស។

**ប្រការ ១៥** : សមាជិកគណបក្ស បាត់បង់សមាជិកភាពរបស់ខ្លួនពីគណបក្សដោយមូលហេតុ៖

- ទទួលមរណភាព
- សុំលាលែងជាលាយលក្ខណ៍អក្សរ ដាក់ជូនប្រធានគណៈកម្មាធិការប្រតិបត្តិគណបក្សរាជធានី-ខេត្ត ឬដាក់ជូនប្រធានគណបក្ស
- ត្រូវបានលុបឈ្មោះចេញពីបញ្ជីសមាជិកភាពគណបក្ស

**ប្រការ ១៦** : ការលុបឈ្មោះចេញពីបញ្ជីសមាជិកភាពគណបក្សចំពោះសមាជិកណាដែលមិនគោរពលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុង សេចក្តីសម្រេចនានា វិន័យរបស់គណបក្ស ឬធ្វើសកម្មភាពផ្ទុយពីផលប្រយោជន៍គណបក្សត្រូវសម្រេចឡើងដោយ៖

- គណៈកម្មាធិការប្រតិបត្តិគណបក្សរាជធានី-ខេត្ត ចំពោះសមាជិកគណបក្សថ្នាក់ក្រោមជាតិ ដោយមានការបើកផ្លូវតវ៉ា រយៈពេលប្រាំពីរ(៧)ថ្ងៃ មកក្រុមប្រឹក្សាវាយតម្លៃ និងវិន័យគណបក្ស ។
- ក្រុមប្រឹក្សាវាយតម្លៃ និងវិន័យ ចំពោះថ្នាក់ដឹកនាំគណបក្សថ្នាក់ជាតិ និងគណៈកម្មាធិការប្រតិបត្តិគណបក្សរាជធានី–ខេត្ត ដោយមានការបើកផ្លូវតវ៉ា រយៈពេលប្រាំពីរ(៧) ថ្ងៃ មកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

នីតិវិធីនៃការលុបឈ្មោះចេញពីបញ្ជីសមាជិកភាពគណបក្ស មានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

## ជំពូកទី ៤
## សិទ្ធិ និងករណីយកិច្ចរបស់សមាជិក

**ប្រការ ១៧ :** សមាជិកគ្រប់រូបរបស់គណបក្ស ត្រូវយល់ព្រមដោយគ្មានលក្ខខណ្ឌ ប្រតិបត្តិឲ្យបានហ្មត់ចត់ នូវវិន័យដូចខាងក្រោម ៖

១- រួបរួមគ្នាជុំវិញគោលនយោបាយរបស់គណបក្ស ដូចមានចែងក្នុងប្រការ៥ នៃលក្ខន្តិកៈ។

២- គោរពរាល់ច្បាប់ និងរាល់សេចក្ដីសម្រេចនានារបស់គណបក្ស។

៣- គោរពទំនៀមទម្លាប់ប្រពៃណីជាតិនិងជួយគ្នាដើម្បីឱ្យសមាជិកគ្រប់ៗរូបកាន់តែមានលក្ខណៈសម្បត្តិល្អប្រសើរឡើងនៅក្នុងការបម្រើ ការពារ និងជួយសម្រាលទុក្ខវេទនារបស់ប្រជាពលរដ្ឋ។

៤- គោរពរាប់អានគ្នា ជួយគ្នា និងទទួលស្គាល់ភាពថ្លៃថ្នូររបស់សមាជិកទាំងអស់ ដោយជៀសវាងគំនិតមើលងាយគ្នា មនោសញ្ចេតនាអាត្មានិយម ឬការប្រកាន់វណ្ណៈតួនាទី និងមើលបំណាំគ្នា។

៥- គោរពសេរីភាព ខាងជំនឿរបស់សមាជិកទាំងអស់ ដោយមិនប្រកាន់ជនជាតិ សាសនា បក្សពួក ឬក្រុមនៅក្នុងគណបក្ស។

## ជំពូកទី ៥
## ធនធានរបស់គណបក្ស

**ប្រការ ១៨ :** ធនធានរបស់គណបក្ស បានមកពី ៖

- វិភាគទានរបស់សមាជិក
- អំណោយពីគ្រប់មជ្ឈដ្ឋានដែលស្របច្បាប់

- សកម្មភាពស្របច្បាប់ក្នុងគ្រប់វិស័យ។

## ជំពូកទី ៦

## រចនាសម្ព័ន្ធរបស់គណបក្ស

**ប្រការ ១៩ :** រចនាសម្ព័ន្ធរបស់គណបក្ស មាន ៖

ក- សមាជគណបក្ស

ខ- គណៈកម្មាធិការនាយកគណបក្ស

គ- គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស

ឃ- រចនាសម្ព័ន្ធគណបក្សនៅមូលដ្ឋាន និងរាជធានី-ខេត្ត

ង- ក្រុមប្រឹក្សាវាយតម្លៃ និងវិន័យ

## ផ្នែកទី ១

## សមាជគណបក្ស

**ប្រការ ២០ :** សមាជគណបក្ស គឺជាស្ថាប័នកំពូលរបស់គណបក្ស។ សមាជចូលរួមដោយប្រតិភូតំណាងសមាជិកគណបក្ស។ សមាជកំណត់ទិសដៅ និងនយោបាយរបស់គណបក្ស ហើយអនុម័តលើសេចក្តីសម្រេចសំខាន់ៗ ដែលគណៈកម្មាធិការនាយកដាក់ជូន។

សមាជជ្រើសតាំងប្រធានគណបក្សតាមរយៈការបោះឆ្នោតដោយមតិភាពច្រើនដាច់ខាត (៥០% +១)នៃសមាជិកវត្តមាន។

សមាជបោះឆ្នោតជ្រើសតាំង សមាជិកគណៈកម្មាធិការនាយកគណបក្ស ដោយមតិភាគច្រើនដាច់ខាត(៥០% +១) នៃសមាជិកវត្តមាន។

សិទ្ធិ និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងប្រធានគណបក្ស និងសមាជិកគណៈកម្មាធិការនាយក មានចែងក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស។

សមាជអាចធ្វើការកែទម្រង់រចនាសម្ព័ន្ធរបស់គណបក្ស។

**ប្រការ ២១ :** សមាជមានពីរប្រភេទ គឺសមាជសាមញ្ញ និងសមាជវិសាមញ្ញ។

១- សមាជសាមញ្ញ ប្រារព្ធធ្វើឡើងជាទៀងទាត់រៀងរាល់ ៥(ប្រាំ) ឆ្នាំម្តង។ កាលបរិច្ឆេទនៃសមាជ កំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណបក្ស។

២- សមាជវិសាមញ្ញ ប្រារព្ធឡើង អាស្រ័យទៅតាមការសម្រេចរបស់ប្រធានគណបក្ស ឬតាមសំណើមតិ ២ភាគ៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស មានភារកិច្ចកោះប្រជុំ និងរៀបចំសមាជទាំងសាមញ្ញ និងវិសាមញ្ញ ហើយសមាជទាំងពីរប្រភេទនេះ ត្រូវតែប្រារព្ធឡើង ក្រោមអធិបតីភាពរបស់ប្រធាន ឬប្រធានស្តីទីគណបក្ស។

**ប្រការ ២២ :** ការអញ្ជើញសមាជិកគណបក្ស មកចូលរួមសមាជ ត្រូវធ្វើក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃជាមុន ចំពោះសមាជសាមញ្ញ និង ០៧(ប្រាំពីរ) ថ្ងៃជាមុន ចំពោះសមាជវិសាមញ្ញ។ សមាជិកគណបក្ស ដែលមានលក្ខណៈជាតំណាង ដែលត្រូវអញ្ជើញមកចូលរួមសមាជ មានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស។

## ជំពូកទី ២

## គណៈកម្មាធិការនាយក

**ប្រការ ២៣ :** គណៈកម្មាធិការនាយក គឺជាស្ថាប័ននីតិប្បញ្ញត្តិរបស់គណបក្ស។ គណៈកម្មាធិការនាយក អនុវត្តទិសទៅ និងនយោបាយរបស់គណបក្សដែលកំណត់ដោយសមាជ។ គណៈកម្មាធិការនាយក ជ្រើសតាំងគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស តាមសំណើរបស់ប្រធានគណបក្ស។ គណៈកម្មាធិការនាយក មានសិទ្ធិដកតួនាទីសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស បើគ្មានការជំទាស់ពីប្រធានគណបក្ស។ គណៈកម្មាធិការនាយក ត្រួតពិនិត្យការប្រតិបត្តិរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស និងអាចផ្តួចផ្តើមគំនិតដឹកនាំគណបក្ស ស្របតាមស្ថានការណ៍ និងកាលៈទេសៈជាក់ស្តែង ដើម្បីឱ្យគណបក្សមានការរីកចម្រើន។

**ប្រការ ២៤ :** គណៈកម្មាធិការនាយក មានសមាជិកយ៉ាងតិច ២៥(ម្ភៃប្រាំ)រូប ដែលត្រូវជ្រើសតាំងដោយសមាជគណបក្សសម្រាប់អាណត្តិ៥(ប្រាំ)ឆ្នាំ។ បញ្ជីបេក្ខជនឈរឈ្មោះគណៈកម្មាធិការនាយកដែលស្នើដោយប្រធានគណបក្ស ត្រូវជ្រើសរើសដោយ៖

- សមាជគណបក្សរាជធានី–ខេត្ត ឬ
- សន្និបាតចលនាយុវជនគណបក្សថ្នាក់រាជធានី–ខេត្ត ឬ
- សន្និបាតចលនាស្ត្រីគណបក្សរាជធានី–ខេត្ត ឬ
- សមាជិកគណៈកម្មាធិការនាយកគណបក្ស ។

**ប្រការ ២៥ :** គណៈកម្មាធិការនាយក អាចមានសមាជិកបន្ថែម តំណាងឲ្យនីតិបុគ្គល ដូចជាចលនាស្ត្រីគណបក្សថ្នាក់ជាតិ ចលនាយុវជនគណបក្សថ្នាក់ជាតិ និងសាខាគណបក្សនៅក្រៅប្រទេស។ ការផ្តល់អាសនៈដែលជាតំណាងនីតិបុគ្គល នៅក្នុងគណៈកម្មាធិការនាយក ត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

**ប្រការ ២៦ :** គណៈកម្មាធិការនាយក បង្កើតក្រុមប្រឹក្សាវាយតម្លៃ និងវិន័យ ដូចមានចែងក្នុងផ្នែកទី ៥ នៃលក្ខន្តិកៈនេះ។

គណៈកម្មាធិការនាយកអនុម័តបទបញ្ជាផ្ទៃក្នុងគណបក្ស។

**ប្រការ ២៧ :** គណៈកម្មាធិការនាយក ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានពីមួយរូប ទៅបីរូប ដែលជាប្រធាន និងអនុប្រធានគណបក្ស។

**ប្រការ ២៨ :** គណៈកម្មាធិការនាយក ជួបប្រជុំគ្នាយ៉ាងតិចបីខែម្តង។ ក្នុងករណីពិសេស ប្រធានគណបក្សឬមតិភាគច្រើនដាច់ខាតនៃសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សឬមតិមួយភាគបីនៃសមាជិកគណៈកម្មាធិការនាយក មានសិទ្ធិកោះប្រជុំគណៈកម្មាធិការនាយក។

## ផ្នែកទី ៣
## គណៈកម្មាធិការអចិន្ត្រៃយ៍

**ប្រការ ២៩ :** គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ត្រូវបង្កើតចេញពីសមាសភាព នៃគណៈកម្មាធិការនាយក ដើម្បីដឹកនាំចាត់ចែង និងអនុវត្តកិច្ចការប្រចាំថ្ងៃរបស់គណបក្ស។ គណៈកម្មាធិការអចិន្ត្រៃយ៍ មានសិទ្ធិសម្រេចលើគ្រប់បញ្ហា និងការងារជាចាំបាច់ រួមទាំងការលុបឈ្មោះចេញពីបញ្ជីសមាជិកភាពគណបក្ស ហើយនិងស្នើសុំឱ្យប្រធានគណបក្សតែងតាំង ឬដកតួនាទីមន្ត្រីគណបក្សគ្រប់លំដាប់ថ្នាក់ ចេញពីតំណែង ឬព្យួរតំណែងមន្ត្រីគណបក្សជាប់ឆ្នោតគ្រប់លំដាប់ថ្នាក់។ គណៈកម្មាធិការអចិន្ត្រៃយ៍ ទទួលខុសត្រូវលើរាល់សេចក្តីសម្រេចទាំងនោះ នៅចំពោះមុខគណៈកម្មាធិការនាយក។

**ប្រការ ៣០ :** គណៈកម្មាធិការអចិន្ត្រៃយ៍ អាចបង្កើតគណៈកម្មការជំនាញនានា ដើម្បីតាមដានបញ្ហាជាតិសំខាន់ៗ ក្នុងគ្រប់វិស័យ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការជំនាញ មានកំណត់នៅក្នុងបទបញ្ជាមួយដោយឡែក។

**ប្រការ ៣១ :** គណៈកម្មាធិការអចិន្ត្រៃយ៍ រៀបចំគម្រោងធំៗ ដាក់ជូនគណៈកម្មាធិការនាយកពិនិត្យមុននឹងដាក់ជូនសមាជអនុម័ត។

**គណៈកម្មាធិការអចិន្ត្រៃយ៍ មានសមាសភាពដូចតទៅ ៖**

- ប្រធានគណបក្ស
- អនុប្រធានគណបក្ស
- អគ្គលេខាធិការគណបក្ស

- អគ្គហេរញ្ញិកគណបក្ស
- សមាជិកមួយចំនួនទៀត ជ្រើសរើសដោយគណៈកម្មាធិការនាយក ពីក្នុងចំណោមសមាជិករបស់ខ្លួន តាមសំណើរបស់ប្រធានគណបក្ស។

**ប្រការ ៣២ :** ប្រធានគណបក្ស ត្រូវជ្រើសតាំងដោយសមាជ តាមរយៈការបោះឆ្នោត ដោយមតិភាគច្រើនដាច់ខាតនៃសមាជិកវត្តមាន សម្រាប់អាណត្តិ៥(ប្រាំ)ឆ្នាំ ហើយមានសិទ្ធិឈរឈ្មោះជាថ្មីទៀត ក្រោយពេលផុតអាណត្តិ។ ឥស្សរជននយោបាយមួយរូបនៅក្នុងគណបក្ស អាចធ្វើជាប្រធានគណបក្សត្រឹមតែ ២ អាណត្តិ (១០ឆ្នាំ) ប៉ុណ្ណោះ។

ប្រធានគណបក្ស គឺជាប្រធានគណៈកម្មាធិការនាយក និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

**ប្រការ ៣៣ :** ប្រធានគណបក្ស តែងតាំង អនុប្រធានយ៉ាងតិចមួយ(១)រូប ក្នុងចំណោមសមាជិកគណៈកម្មាធិការនាយក បន្ទាប់ពីមានការយល់ព្រមពីមតិភាគច្រើនដាច់ខាត នៃគណៈកម្មាធិការនាយកសម្រាប់អាណត្តិ៥(ប្រាំ)ឆ្នាំ។ អនុប្រធានគណបក្ស ទទួលដឹកនាំការងារគណបក្សតាមការកំណត់របស់ប្រធាន។ នៅពេលអវត្តមាន របស់ប្រធានគណបក្ស អនុប្រធាន ០១រូប ត្រូវបានប្រគល់សិទ្ធិដោយប្រធាន ជាប្រធានស្តីទីគណបក្ស។

**ប្រការ ៣៤ :** ប្រធានគណបក្ស មានខុទ្ទកាល័យមួយ ដើម្បីជួយដល់កិច្ចការផ្ទាល់របស់ប្រធាន។ ខុទ្ទកាល័យប្រធានគណបក្ស ដឹកនាំដោយនាយក ០១រូប អមដោយនាយករងមួយចំនួនដែលតែងតាំងដោយប្រធានគណបក្ស។

ប្រធានគណបក្ស មានសិទ្ធិតែងតាំង ឬផ្លាស់ប្តូរបេក្ខជនតំណាងរាស្ត្រ បេក្ខជនព្រឹទ្ធសភា ឬថ្នាក់ដឹកនាំសាខាគណបក្សនៅក្រៅប្រទេស តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

ប្រធានគណបក្ស មានសិទ្ធិតែងតាំង ឬដកតួនាទី បេសកជន និងទីប្រឹក្សាផ្ទាល់របស់ខ្លួន។

**ប្រការ ៣៥ :** ទីប្រឹក្សាទាំងអស់របស់ប្រធានគណបក្ស អាចបង្កើតក្រុមការងារតាមវិស័យផ្សេងៗ ដើម្បីផ្តល់អនុសាសន៍ជូនប្រធានគណបក្ស។

**ប្រការ ៣៦ :** ក្នុងករណីប្រធានគណបក្ស បាត់បង់សមត្ថភាពដឹកនាំគណបក្ស ដែលសម្រេចដោយគណៈកម្មាធិការនាយក ៖

- អនុប្រធាន មួយរូប ត្រូវទទួលតួនាទីជាប្រធានស្តីទីគណបក្ស

- យ៉ាងយូរបំផុតក្នុងរយៈពេលសាមសិបថ្ងៃ គណៈកម្មាធិការនាយក ត្រូវជ្រើសរើសប្រធានគណបក្សថ្មី ក្នុងចំណោមសមាជិកគណៈកម្មាធិការនាយក ដើម្បីដឹកនាំការងារគណបក្សបន្តរហូតដល់ចប់អាណត្តិ។

**ប្រការ ៣៧ :** ប្រធានគណបក្ស តែងតាំងអគ្គលេខាធិការ ពីក្នុងចំណោមសមាជិកគណៈកម្មាធិការនាយក បន្ទាប់ពីមានការយល់ព្រមដោយមតិភាគច្រើនដាច់ខាត នៃគណៈកម្មាធិការនាយក។

ប្រធានគណបក្ស តែងតាំងតាមសំណើរបស់អគ្គលេខាធិការនូវ ៖

- អគ្គលេខាធិការរង
- ប្រធាន អនុប្រធាននាយកដ្ឋានក្នុងអគ្គលេខាធិការដ្ឋាន។

តាមសំណើរបស់អគ្គលេខាធិការ ប្រធានគណបក្ស ទទួលស្គាល់សមាសភាពគណៈកម្មាធិការប្រតិបត្តិគណបក្សរាជធានី-ខេត្ត សមាសភាពថ្នាក់ដឹកនាំចលនាយុវជនថ្នាក់ជាតិ និងសមាសភាពថ្នាក់ដឹកនាំចលនាស្ត្រីថ្នាក់ជាតិ។

**ប្រការ ៣៨ :** អគ្គលេខាធិការគ្រប់គ្រង និងធានាការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋាន ចលនាយុវជនគណបក្ស ចលនាស្ត្រីគណបក្ស រចនាសម្ព័ន្ធគណបក្សនៅមូលដ្ឋាននិងរាជធានី-ខេត្ត និងសាខាគណបក្សនៅក្រៅប្រទេស។

អគ្គលេខាធិការ អនុវត្តការងារប្រចាំថ្ងៃមួយផ្នែកធំរបស់គណបក្ស ក្រោមការត្រួតពិនិត្យរបស់ប្រធាន និងអនុប្រធានគណបក្ស។

ការរៀបចំ និងការប្រព្រឹត្តទៅ នៃចលនាយុវជនគណបក្ស និងចលនាស្ត្រីគណបក្ស កំណត់ដោយគណៈកម្មាធិការនាយកគណបក្ស។

**ប្រការ ៣៩ :** អគ្គលេខាធិការ មានអគ្គលេខាធិការរងមួយចំនួន ដើម្បីជួយកិច្ចការរបស់ខ្លួន។ អគ្គលេខាធិការរង ទទួលការងារតាមការកំណត់របស់អគ្គលេខាធិការ។ ក្នុងករណីអគ្គលេខាធិការអវត្តមាន អគ្គលេខាធិការរង០១រូប ត្រូវបានប្រគល់សិទ្ធិដោយ អគ្គ-លេខាធិការ ជាអគ្គលេខាធិការស្តីទី។

អាណត្តិរបស់អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវបញ្ចប់ស្របនឹងអាណត្តិរបស់ប្រធានគណបក្ស។

**ប្រការ ៤០ :** ប្រធានគណបក្ស តែងតាំងអគ្គហេរញ្ញិក ពីក្នុងចំណោមសមាជិកគណៈកម្មាធិការនាយក បន្ទាប់ពីមានការយល់ព្រមដោយមតិភាគច្រើនដាច់ខាត នៃគណៈកម្មាធិការនាយក សម្រាប់អាណត្តិ ៥(ប្រាំ)ឆ្នាំ។

**ប្រការ ៤១ :** អគ្គហេរញ្ញិកទទួលគ្រប់គ្រងថវិកា និងបញ្ជីសារពើភ័ណ្ឌទាំងអស់របស់គណបក្ស។

អគ្គហេរញ្ញិក មានអគ្គហេរញ្ញិករងមួយរូបដើម្បីជួយកិច្ចការរបស់ខ្លួន។ ក្នុងករណី អគ្គហេរញ្ញិកអវត្តមាន អគ្គហេរញ្ញិករង ត្រូវបានប្រគល់សិទ្ធិ ដោយអគ្គហេរញ្ញិកជាអគ្គហេរញ្ញិកស្តីទី។

អគ្គហេរញ្ញិករង តែងតាំងដោយប្រធានគណបក្សតាមសំណើរបស់អគ្គហេរញ្ញិក។

**ប្រការ ៤២ :** អគ្គហេរញ្ញិកត្រូវធ្វើរបាយការណ៍ប្រចាំខែស្តីពីប្រាក់ចំណូល-ចំណាយរបស់គណបក្សជូនប្រធាន អនុប្រធាន អគ្គលេខាធិការ និងសមាជិកគណៈកម្មាធិការនាយក។ ប្រធានគណបក្ស មានសិទ្ធិកោះហៅអគ្គហេរញ្ញិក មករាយការណ៍គ្រប់ពេលវេលា ទៅតាមការចាំបាច់។

**ប្រការ ៤៣ :** គណៈកម្មាធិការនាយកជ្រើសរើសស្ទង់ការគណនេយ្យតាមសំណើរបស់ក្រុមប្រឹក្សាវាយតម្លៃ និងវិន័យ ដើម្បីត្រួតពិនិត្យភាពមិនប្រក្រតីលើបញ្ជីចំណូល និងចំណាយរបស់គណបក្ស។

## ផ្នែកទី ៤
## រចនាសម្ព័ន្ធគណបក្សនៅមូលដ្ឋាន និងរាជធានី-ខេត្ត

**ប្រការ ៤៤ :** រចនាសម្ព័ន្ធគណបក្សនៅមូលដ្ឋាន និងរាជធានី-ខេត្ត មានបណ្តាញគណបក្សភូមិ គណៈកម្មាធិការប្រតិបត្តិគណបក្សឃុំ-សង្កាត់ គណៈកម្មាធិការប្រតិបត្តិគណបក្សក្រុង-ស្រុក-ខណ្ឌ និងគណៈកម្មាធិការប្រតិបត្តិគណបក្សរាជធានី-ខេត្ត។

នីតិវិធីនៃការរៀបចំរចនាសម្ព័ន្ធគណបក្សនៅមូលដ្ឋាន និងរាជធានី-ខេត្ត មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស។

## ផ្នែកទី ៥
## ក្រុមប្រឹក្សាវាយតម្លៃ និងវិន័យ

**ប្រការ ៤៥ :** ក្រុមប្រឹក្សាវាយតម្លៃ និងវិន័យត្រូវបានបង្កើតឡើង ដោយគណៈកម្មាធិការនាយកគណបក្ស។

ក្រុមប្រឹក្សាវាយតម្លៃ និងវិន័យ មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ចងក្រងវិន័យគណបក្ស ហើយសុំការអនុញ្ញាត ពីគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីដាក់ឱ្យសមាជិកគណបក្សគ្រប់លំដាប់ថ្នាក់ប្រតិបត្តិ។
- ពិនិត្យ និងតាមដានរាល់សកម្មភាពរបស់សមាជិកគណបក្សនៅតាមគ្រប់លំដាប់ថ្នាក់។

- វាយតម្លៃនូវផលប្រយោជន៍ ឬគុណវិបត្តិ នៃសកម្មភាពនានារបស់សមាជិកគណបក្ស ហើយរៀបចំសំណុំរឿង ដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងសម្រេច ក្នុងការផ្តល់មេដាយ ឬការក្រើនរំលឹក និងថ្កោលទោស ។
- ទទួលញត្តិ របស់សមាជិកគណៈកម្មាធិការប្រតិបត្តិគណបក្សរាជធានី-ខេត្ត ដើម្បីធ្វើការស៊ើបអង្កេត និងទទួលពាក្យបណ្តឹងនានា របស់សមាជិកគណបក្ស ដែលមានវិវាទនឹងគ្នា ដើម្បីផ្សះផ្សា និងដោះស្រាយ។ ក្នុងករណីមិនអាចផ្សះផ្សា ឬដោះស្រាយបាន ត្រូវធ្វើរបាយការណ៍ជូន គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សដើម្បីពិនិត្យ និងសម្រេច។
- ទទួល និងដោះស្រាយពាក្យបណ្តឹងឧទ្ធរណ៍របស់សមាជិកគណបក្សដែលតវ៉ានឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិរាជធានី–ខេត្តគណបក្ស ។

**ប្រការ ៤៦** : ក្រុមប្រឹក្សាវាយតម្លៃ និងវិន័យ មាន ៖

- ប្រធាន ០១រូប ជ្រើសរើសដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ពីក្នុងចំណោមសមាជិករបស់ខ្លួន
- អនុប្រធាន ០១រូប ជ្រើសរើសដោយគណៈកម្មាធិការនាយក ពីក្នុងចំណោមសមាជិករបស់ខ្លួន
- សមាជិក ០៣រូបទៀត ជ្រើសរើសពីមជ្ឈដ្ឋានផ្សេងៗ ក្នុងគណបក្សដោយគណៈកម្មាធិការនាយក តាមសំណើរបស់ប្រធានគណបក្ស។

ក្រុមប្រឹក្សាវាយតម្លៃ និងវិន័យទាំងបីរូប មានសិទ្ធិចូលរួមប្រជុំ និងបញ្ចេញមតិក្នុងអង្គប្រជុំរបស់គណៈកម្មាធិការនាយក តែគ្មានសិទ្ធិបោះឆ្នោត។

កិច្ចប្រជុំ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវាយតម្លៃ និងវិន័យអាចយកជាការបានលុះត្រាតែមានសំឡេងគាំទ្រលើស ៥០% នៃសមាជិកក្រុមប្រឹក្សាវាយតម្លៃ និងវិន័យទាំងមូល។

**ប្រការ ៤៧** : ក្រុមប្រឹក្សាវាយតម្លៃ និងវិន័យ មានសិទ្ធិលុបឈ្មោះចំពោះសមាជិកគណបក្សរូបណា រួមទាំងសមាជិកគណៈកម្មាធិការប្រតិបត្តិគណបក្សរាជធានី-ខេត្ត ឬសមាជិកគណៈកម្មាធិការនាយក ដែលរំលោភលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬសេចក្តីសម្រេចនានា ឬធ្វើសកម្មភាពផ្ទុយពីផលប្រយោជន៍គណបក្ស ។

**ប្រការ ៤៨** : ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាវាយតម្លៃ និងវិន័យមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស។

## ជំពូកទី ៧

## ការកែប្រែលក្ខន្តិកៈ និងការរំលាយគណបក្ស

**ប្រការ ៤៩ :** គណបក្សអាចប្តូរឈ្មោះ និងកែប្រែលក្ខន្តិកៈរបស់ខ្លួនបាន តាមរយៈសមាជគណបក្ស ដោយមានសំឡេងគាំទ្រភាគច្រើនដាច់ខាត(៥០% +១) នៃសមាជិកវត្តមាន។

**ប្រការ ៥០ :** គណបក្សអាចរំលាយ ឬបង្រួបបង្រួម ជាមួយគណបក្សដទៃទៀតបាន តាមរយៈសមាជគណបក្ស ដោយមានសំឡេងគាំទ្រភាគច្រើនដាច់ខាត នៃសមាជិកចូលរួម។ ក្នុងករណីដែលកាលៈទេសៈមិនអំណោយផល ហើយមិនអាចរៀបចំសមាជបាន ប្រធានគណៈបក្សអាចប្រកាសរំលាយ ដោយផ្អែកលើសំឡេងគាំទ្រភាគច្រើនដាច់ខាត នៃសមាជិកគណៈកម្មាធិការនាយកគណបក្ស។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**ប្រការ ៥១ :** អន្តរប្បញ្ញត្តិគឺជាបញ្ញត្តិសម្រាប់អនុវត្តនៅក្នុងអន្តរកាល។ អន្តរកាលគឺជាដំណាក់កាលនៃការគ្រប់គ្រង និងដឹកនាំគណបក្សនៅក្នុងស្ថានភាពដែលគណបក្សមិនទាន់បានទទួលជោគជ័យក្នុងការដឹកនាំប្រទេស ។

**ប្រការ ៥២ :** សមាជគណបក្សនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ អនុម័តបញ្ជីបេក្ខជនសមាជិកគណៈកម្មាធិការនាយកតាមសំណើរបស់ប្រធានគណបក្ស ដោយសំឡេងភាគច្រើនដាច់ខាតនៃសមាជិកវត្តមាន។

**ប្រការ ៥៣ :** នៅក្នុងអន្តរកាលនេះ៖

- គណៈកម្មាធិការនាយកគណបក្ស សម្រេចដោយមតិភាគច្រើនដាច់ខាត ក្រៅពេលធ្វើសមាជគណបក្ស
- គណៈកម្មាធិការនាយកសម្រេចដោយសំឡេងភាគច្រើនដាច់ខាត(៥០%+១) ដកតួនាទី ឬជ្រើសតាំងបន្ថែមសមាជិកគណៈកម្មាធិការនាយក តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**ប្រការ ៥៤** : លក្ខន្តិកៈនេះ ចូលជាធរមានប្បញ្ញត្តិបន្ទាប់ពីបានអនុម័តការធ្វើវិសោធនកម្ម ដោយសមាជថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ ហើយបានជំនួសលក្ខន្តិកៈ ដែលអនុម័តដោយសមាជថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨។

**ប្រការ ៥៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីលក្ខន្តិកៈនេះ ត្រូវទុកជានិរាករណ៍។

**ថ្ងៃសៅរ៍ ៨រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥**

**រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០២១**

**ប្រធានគណបក្ស**

**ទាវ វណ្ណុល**

**បានតម្កល់ទុកលក្ខន្តិកៈ**

របស់

**គណបក្សភ្លើងទៀន**

ដែលបានធ្វើវិសោធនកម្មលក្ខន្តិកៈតាមលិខិតលេខៈ ៥៧.៩......សជណ

ចុះថ្ងៃ ពុធ ៧ កើត...........ខែ ផល្គុន.....ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ត្រូវនឹងថ្ងៃទី ០៩..... ខែ មីនា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ។

ថ្ងៃ ពុធ ៧ កើត.......ខែ ផល្គុន...ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៩..... ខែ មីនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណបក្ស ភ្លើងទៀន
CANDLE LIGHT PARTY

## ឧបសម្ព័ន្ធ ១

## សញ្ញាសម្គាល់គណបក្ស

គណបក្ស ភ្លើងទៀន

**បាវចនាគណបក្ស ៖ សីលធម៌ សច្ចធម៌ និងយុត្តិធម៌**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខៈ ៤៧៤ សជណ

ថ្ងៃ ពុធ ៧កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០២២

**ជម្រាបមក**
**លោក ទាវ វណ្ណុល**
**ប្រធានគណបក្សភ្លើងទៀន**

**កម្មវត្ថុ** ៖ ស្តីពីការជូនដំណឹងអំពីលទ្ធផលសមាជវិសាមញ្ញរបស់គណបក្សភ្លើងទៀន កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១។

**យោង** ៖
- ច្បាប់ស្តីពីគណបក្សនយោបាយ
- ប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ២០២៤ សជណ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ៥០០ សជណ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ៣៦០ សជណ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ០១៤/២២ គភទ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ របស់គណបក្សភ្លើងទៀន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានគណបក្សថា ក្រសួងមហាផ្ទៃ សម្រេចទទួលស្គាល់នូវលទ្ធផលសមាជវិសាមញ្ញគណបក្សភ្លើងទៀន ដែលបានប្រារព្ធធ្វើកាលពីថ្ងៃសៅរ៍ ៨រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយបានធ្វើវិសោធនកម្មលក្ខន្តិកៈគណបក្ស ស្របតាមលក្ខខណ្ឌកំណត់ក្នុងលក្ខន្តិកៈគណបក្សតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងបានបញ្ជូននូវបញ្ជីឈ្មោះសមាសភាពថ្នាក់ដឹកនាំ និងជីវប្រវត្តិសង្ខេបរបស់ថ្នាក់ដឹកនាំអាណត្តិថ្មី តាមការកំណត់ក្នុងលក្ខន្តិកៈគណបក្ស ជូនមកក្រសួងមហាផ្ទៃ ស្របតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីគណបក្សនយោបាយផងដែរ។

អាស្រ័យហេតុនេះ សូម លោកប្រធានគណបក្ស ជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

សូម លោកប្រធាន ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន:**
- តុលាការកំពូល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ក្រសួងយុត្តិធម៌
- សាលារាជធានីភ្នំពេញ
  (ដើម្បីជូនជ្រាប)
- ឯកសារ - កាលប្បវត្តិ

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh